ទីស្តីការក្រសួងយុត្តិធម៌

លេខ ០១ សរ.បរ-៩៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើចំពោះ**

**លោកប្រធានតុលាការ ខេត្ត ក្រុងទូទាំងប្រទេស**

**កម្មវត្ថុ:** អំពីចំណាត់ការរបស់តុលាការខេត្ត-ក្រុង ក្រោយពីភាគីបានប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់ខ្លួន ។

ក្នុងរយៈកាលកន្លងទៅនេះក្រសួងយុត្តិធម៌បានសង្កេតឃើញជាញឹកញាប់ថា គូភាគីទាំងឡាយដែលត្រូវបានតុលាការ ខេត្ត ក្រុង សម្រេចសេចក្តីចេញជាសាលក្រមរួចហើយ ហើយមានភាគីម្ខាង ឬទាំងសងខាងមិនសុខចិត្តបានប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនោះ ភាគីម្ខាង ឬទាំងសងខាងតែងតែប្រើសិទ្ធិរំលោភដូចជា សង់សំណង់ ឬរុះរើសំណង់ ឬកាន់កាប់ដីធ្លីដែលកំពុងទំនាស់គ្នាជាដើម ។

ក្រសួងសូមរំលឹកដល់ប្រធានតុលាការខេត្ត ក្រុង ទាំងអស់គ្រប់សេចក្តីសម្រេចរបស់តុលាការខេត្ត ក្រុង ដែលត្រូវបានភាគីម្ខាង ឬទាំងសងខាងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ សេចក្តីសម្រេចនោះមិនអាចយកទៅអនុវត្តបានឡើយ បានន័យថា ត្រូវរក្សាទុកវត្ថុដែលមានទំនាស់អោយនៅភាពដូចដើមជានិច្ច ដ៏រាបណាសាលាឧទ្ធរណ៍មិនទាន់បានសម្រេច អំពីរឿងនោះនៅឡើយ ។ ម្យ៉ាងទៀតក្នុងការសម្រេចសេចក្តីចេញជាសាលក្រមចៅក្រមជម្រះក្តីទាំងឡាយត្រូវតែរំលឹកក្នុងសេចក្តីសម្រេចរបស់ខ្លួនថា បណ្តឹងឧទ្ធរណ៍ត្រូវផ្អាកការអនុវត្តន៍សាលក្រមរបស់តុលាការខេត្ត ក្រុង។

ក្នុងករណីមានភាគីណាមួយបានប្តឹងឧទ្ធរណ៍ពីសាលក្រមនោះរួចហើយ ហើយភាគីម្ខាងទៀតនៅតែរំលោភដោយយកសាលក្រមនោះទៅអនុវត្ត ឬធ្វើអោយប្រែភាពដើមនៃវត្ថុទំនាស់នោះ ប្រធានតុលាការត្រូវតែចេញដីកាហាមឃាត់ជននោះអំពីអំពើខុសច្បាប់ដែលជននោះបានប្រព្រឹត្ត ហើយបង្គាប់អោយជននោះផ្អាកសកម្មភាពរបស់ខ្លួនជាបន្ទាន់ ។ នៅពេលដែលសាលាឧទ្ធរណ៍ចាប់ដំណើរការនោះឧប្បត្តិហេតុទាំងឡាយដែលកើតចេញពីការអនុវត្តន៍សាលក្រមតុលាការខេត្ត ក្រុង ដែលភាគីបានប្តឹងឧទ្ធរណ៍នោះជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ។

ក្រសួងសង្ឃឹមថា សេចក្តីណែនាំខាងលើនេះអាចជួយដល់ប្រធានតុលាការខេត្ត-ក្រុង ក្នុងការទប់ស្កាត់នូវអំពើរំលោភច្បាប់ដែលកើតមានជារឿយៗ ពីបណ្តាភាគីទាំងឡាយក្នុងរឿងក្តី។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤

រដ្ឋមន្ត្រី

**ចែម ស្គួន**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ

-តុលាការកំពូល និងមហាអយ្យការ

-អភិបាលខេត្ត ក្រុង

-ដើម្បីជ្រាប